# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

(ASPIRE)

IFAD Loan No. 2000000744 និងASAP Trust Grant No. 2000000743

# គោលការណ៍ណែនាំ សម្រាប់ថ្នាលបណ្តុះពូជដំណាំ

## GUIDELINE FOR TREE NURSERY




ខែមីនា ឆ្នាំ២០១៧

រៀបចំដោយ៖ASPIRE/Sec.

ឧបត្ថម្ភដោយ៖ រាជរដ្ឋាភិបាលកម្ពុជា និងIFAD

# អារម្ភកថា

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការគាំទ្រពីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) បានផ្តល់ថវិកាដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត សមាសភាគទី ៣ នៃកម្មវិធីគឺ ការធ្វើឲ្យប្រសើរឡើងនូវសេវាផ្សព្វផ្សាយ តាមរយៈការអនុវត្តសកម្មភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។

ឯកសារ**គោលការណ៍ណែនាំសម្រាប់ថ្នាលបណ្តុះពូជដំណាំ**នេះបានចងក្រងដោយអ្នកជំនាញបច្ចេកទេសនឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីមន្ត្រីបច្ចេកទេសនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិព័ណ៌នាដំណើរការអនុវត្តថ្នាលបណ្តុះពូជដំណាំសម្រាប់ជួយដល់មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីការិយាល័យកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ នៅមូលដ្ឋានយកទៅប្រើប្រាស់ និងធ្វើការងារជាមួយកសិករក្នុងការអនុវត្តថ្នាលបណ្តុះពូជដំណាំ នៅក្នុងតំបន់គោលដៅ ក្នុងគោលបំណង បង្កើនសន្តិសុខស្បៀង ការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀងអាហារ និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដោយបន្តលើកកម្ពស់វិស័យកសិកម្មក្នុងសន្ទុះនិងទំហំថ្មីមួយ ដើម្បីពង្រឹងនិងពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ច បង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)គាំទ្រនូវឯកសារ**គោលការណ៍ណែនាំសម្រាប់ថ្នាលបណ្តុះពូជដំណាំ** ដែលជាគោលការណ៍សម្រាប់មន្ត្រីកសិកម្មស្រុកខេត្តយកទៅអនុវត្ត និងសហការ និងអនុវត្តកម្មវិធីជាមួយ ប្រជាកសិករបានទូលំទូលាយនិងទទួលបានលទ្ធផលល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

# ក្រុមនិពន្ធ និងរៀបចំគោលការណ៍ណែនាំ

គោលការណ៍ណែនាំសម្រាប់ថ្នាលបណ្តុះពូជដំណាំ នេះត្រូវបានរៀបចំចងក្រងឡើងដោយមានការណែនាំពីលេខាធិការដ្ឋានកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)ក្រោមការឧបត្ថម្ភគាំទ្រពីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម និងរាជរដ្ឋាភិបាលកម្ពុជា ។

ឯកសារនេះបានរៀបចំឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ មានទីប្រឹក្សាកម្មវិធី ប្រធាន អនុប្រធាននិង មន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងខេត្តគោលដៅនៃកម្មវិធី ដោយមានការចូលរួមកែលម្អ ផ្តល់មតិយោបល់ លើពាក្យពេជន៍ខ្លឹមសារក្នុងនោះមាន លោក សាយ តុម លោកសៃ សុភី លោកជិន ប៊ុនរិទ្ធ លោកគាម ហាន លោកព្រំ វិមាន លោក ហៃ ផូរ៉ា លោកហ៊ន់ សុវណ្ណ លោកមាស ពិសិដ្ឋ លោកលី ឈាន លោកហង់ សុភា លោកស្រី យឹម សំណាង និងអ្នកផ្តល់យោបល់ផ្សេងៗទៀតដែលមិនបានរាប់ឈ្មោះខាងលើ។ ជាពិសេសការចូលរួមរចនាឯកសារគោលការណ៍ណែនាំនេះ មាន លោកជឹម លីនណា លោកប៉ូល ច័ន្ទរិទ្ធី លោកយឹម សុខសុភាស់ ដែលបានជួយពិនិត្យនិងកែសម្រួលលើគុណភាពរូបភាពបន្ថែមឲ្យកើតចេញនិងបោះពុម្ពឯកសារនេះឡើង។

ឯកសារគោលការណ៍ណែនាំនេះនឹងបន្តកែលម្អដើម្បីឆ្លើយតបនឹងការអនុវត្តនៅមូលដ្ឋាននិងការចាំបាច់នានា ។ សូមទទួលយកយោបល់ និងមតិពីឯកឧត្តម លោក លោកស្រីដើម្បីកែលម្អលើខ្លឹមសារនិងសំណូរពរផ្សេងៗលើគោលការណ៍ណែនាំនេះ សូមធ្វើការទំនាក់ទំនងមកលេខាធិការដ្ឋានកម្មវិធី ឬតាមអាសយដ្ឋានដូចខាងក្រោម៖

## ក្រុមអ្នកនិពន្ធ៖

| | |
|---|---|
| ១. លោក ស៊ុន វណ្ណ | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត ( ដឹកនាំរៀបចំគោលការណ៍ណែនាំ ) |
| ២. លោក លោកស្រី | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត |

## ត្រួតពិនិត្យ និងកែសម្រួលដោយ៖

| | |
|---|---|
| ១. លោកបណ្ឌិត ម៉ាក សឿន | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម និងជាប្រធានកម្មវិធីស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម |
| ២. លោក ហុក គឹមធួន | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ និងជាប្រធានក្រុមគាំទ្រលេខាធិការដ្ឋាននៃកម្មវិធី (ASPIRE) |

**បោះពុម្ពលើកទី១ ដោយៈ**
លេខាធិការដ្ឋាន នៃកម្មវិធី (ASPIRE) ក្រោមមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD) និង ឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា
អាសយដ្ឋានៈ # ២០០ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
( ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ )
លេខទូរស័ព្ទៈ ០២៣ ២២ ១១ ២០
គេហទំព័រៈ WWW.ASPIREKH.ORG

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំសម្រាប់ថ្នាលពូជដំណាំនេះ បានរៀបចំឡើងដោយមានការជ្រោមជ្រែងពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលដឹកនាំដោយ **ឯកឧត្តមម៉ម អំណាត់** រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកកម្មវិធី និងក្រោមការផ្តួចផ្តើមដឹកនាំដោយ លោក **ហុក គឹមធួន** ប្រធានក្រុមគាំទ្រលេខាធិការដ្ឋាននៃកម្មវិធី(ASPIRE)ដែលបានលើកទឹកចិត្តនិងជ្រោមជ្រែងឲ្យមានការរៀបចំដាក់ចេញជាគោលការណ៍ណែនាំសម្រាប់ថ្នាលបណ្តុះពូជដំណាំដើម្បីយកមកអនុវត្តឲ្យមានប្រសិទ្ធភាពតាមតំបន់គោលដៅនៃកម្មវិធីទាំងមូល។ការរៀបចំគោលការណ៍នេះទៅបានដោយសារម្ចាស់ជំនួយមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD) ដែលបានផ្តល់ថវិកាកម្ចីដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)មានគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារ កសិករខ្នាតតូចក្រីក្រនិងងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា។

យើងខ្ញុំសូមថ្លែងអំណរគុណ ជាពិសេសដល់លោក លោកស្រីប្រធាន អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងសហការីគ្រប់ខេត្តទាំងអស់នៃកម្មវិធីដែលបានចូលរួមមតិកែលម្អ ទាំងខ្លឹមសារអត្ថន័យ និងផ្តល់ជារូបភាពល្អៗដើម្បីដាក់បញ្ចូលក្នុងគោលការណ៍ណែនាំនេះឲ្យមានខ្លឹមសារកាន់តែឆ្លុះបញ្ចាំងនូវការអនុវត្តជាក់ស្តែង ក៏ដូចជាយន្តការដែលអាចយកមកអនុវត្តនៅទីវាលបានល្អប្រសើរ ការផ្តល់មតិកែលម្អទាំងអស់នេះបានរួមចំណែកធ្វើឲ្យការរៀបចំគោលការណ៍នេះកាន់តែមានភាពល្អប្រសើរ ។

សូមថ្លែងអំណរគុណជាពិសេសដល់ បណ្ឌិត**ម៉ាក់ សឿន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម និងជាប្រធានកម្មវិធីស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម លោក**ហុក គឹមធួន** ប្រធានក្រុមគាំទ្រលេខាធិការដ្ឋានកម្មវិធីក្នុង ការតម្រង់ទិស និងកែលម្អដើម្បីសម្រេចបាននូវគោលការណ៍នេះយកមកប្រើប្រាស់នាពេលនេះ និងសូមអរគុណដល់សហការី និងទីប្រឹក្សាកម្មវិធីទាំងអស់ ក៏ដូចជាភ្នាក់ងារវិស័យឯកជនសាធារណៈដែលបានរួមចំណែកផ្តល់យោបល់ និងរូបភាពសំខាន់ៗដើម្បីយកមកប្រើប្រាស់ក្នុងគោលការណ៍ណែនាំនេះ។

ទោះបីជាយ៉ាងក៏ដោយ ឯកសារនេះជាមូលដ្ឋានដែលអាចបត់បែនបានតាមកាលៈទេសៈ ពេលវេលា និងទីតាំងភូមិសាស្ត្រដើម្បីធ្វើឲ្យការអនុវត្តទទួលបានលទ្ធផលល្អប្រសើរស្របតាមគោលបំណងនៃកម្មវិធី។ ក្នុងនាមក្រុមការងាររៀបចំគោលការណ៍នេះ យើងខ្ញុំសូមស្វាគមន៍ និងទទួលយកនូវមតិកែលម្អប្រកបដោយន័យស្ថាបនាដើម្បីឲ្យគោលការណ៍នេះកាន់តែឆ្លុះបញ្ចាំង និងឆ្លើយតបនូវការអនុវត្តជាក់ស្តែងនៅមូលដ្ឋាន។

**ពីក្រុមការងារនៃលេខាធិការដ្ឋានកម្មវិធី**

# មាតិកា

**អារម្ភកថា**......................................................................................................................i

**ក្រុមនិពន្ធ និងរៀបចំគោលការណ៍ណែនាំ**..........................................................ii

**សេចក្តីថ្លែងអំណរគុណ** ..........................................................................................iv

**១. សេចក្តីផ្តើម**..........................................................................................................1

**២គោលបំណងនៃការរៀបចំថ្នាលបណ្តុះពូជដំណាំ** ..................................................1

**៣វិធីសាស្ត្រអនុវត្ត** ....................................................................................................2

**៤ដំណើរការរៀបចំថ្នាលបណ្តុះពូជដំណាំ** ..................................................................2

**៥ការរៀបចំផែនការសកម្មភាព . និងកិច្ចសន្យា**..........................................................4

**៦ការបែងចែកកូនដំណាំដល់សមាជិកទទួលផល** .......................................................5

**៧តាមដានអនុវត្តសកម្មភាព និងតម្រង់ទិស** ..............................................................5

ឧបសម្ព័ន្ធទី១៖ គំរូកិច្ចសន្យាសម្រាប់ថ្នាលបណ្តុះពូជដំណាំ..............................................6

ឧបសម្ព័ន្ធទី២៖ គំរូផែនការសកម្មភាព និងថវិកា.............................................................9

ឧបសម្ព័ន្ធទី៣៖ គំរូតារាងតាមដានការកត់ត្រាចំនួនកូនដំណាំ ..........................................9

## ១. សេចក្តីផ្តើម

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការគាំទ្រពីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដែលមានរយៈពេល៧ឆ្នាំ ។ កម្មវិធីបានចាប់ផ្តើមអនុវត្តពីខែសីហា ឆ្នាំ២០១៥ ដល់ ឆ្នាំ២០២១ រហូតមកដល់ពេលនេះ មានរយៈពេលជិត២ឆ្នាំដែលមានគោលបំណង លើកកម្ពស់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដែលឆ្លើយតបទៅនឹងតម្រូវការរបស់កសិករខ្នាតតូចក្រីក្រ និងងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះនឹងជួយដល់កសិករខ្នាតតូច ជាពិសេសកសិករក្រីក្រ និងកសិករងាយរងគ្រោះស្ត្រីមេម៉ាយ និងយុវកសិករក្នុងការអភិវឌ្ឍន៍ការងារកសិកម្មឲ្យប្រែក្លាយទៅជាការងារធុរកិច្ចដែលមានភាពធន់ និងទទួលបានប្រាក់ចំណេញ។ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាភ្នាក់ងារប្រតិបត្តិដោយមានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិបាននិងកំពុងអនុវត្តសមាសភាគទី១ លើការសិក្សារៀបចំគោលនយោបាយ រីឯលេខាធិការដ្ឋាននៃ ជ.អ.ជ.ប បាននិងកំពុងអនុវត្តលើសមាសភាគទី៤ ការកសាងហេដ្ឋាសម្ព័ន្ធកសិកម្មដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ កម្មវិធីសាកល្បងលើតំបន់គោលដៅចំនួន៥ខេត្ត មានខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង ក្រចេះ និងព្រះវិហារ និងការពង្រីកតំបន់គោលដៅទៅកាន់ខេត្ត៥ទៀតនៅឆ្នាំ២០១៨ មានខេត្តកំពត កណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ នៅពេលដែលគម្រោង PADEE ត្រូវបានបញ្ចប់។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំពុងអនុវត្តអនុកម្មវិធី-សមាសភាគទី៣ ការលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម។ ដោយបានទទួលការអនុម័តលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៧ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវរៀបចំថ្នាលបណ្តុះពូជដំណាំចំនួនមួយ ឬច្រើនកន្លែងស្របតាមផែនការដែលបានអនុម័ត។ ថ្នាលបណ្តុះពូជដំណាំទាំងនេះមានទីតាំងនៅតាមសហគមន៍គោលដៅដើម្បីផលិតពូជកូនដំណាំជាលក្ខណៈអាជីវកម្ម។

គោលការណ៍ណែនាំនេះរៀបរាប់ពីគោលបំណង ដំណើរការ ការជ្រើសរើសទីតាំងថ្នាល ការជ្រើសរើសកសិករដែលមានសក្តានុពល ការជ្រើសរើសសមាជិកទទួលផលពីថ្នាល និងការគាំទ្រដល់ការរៀបចំថ្នាលទាំងមូលឲ្យដំណើរការបានជោគជ័យ ។

## ២. គោលបំណងនៃការរៀបចំថ្នាលបណ្តុះពូជដំណាំ

ថ្នាលបណ្តុះពូជដំណាំមានលក្ខណៈជាសហគ្រាសអាជីវកម្មនេះ មានគោលបំណងចំនួនពីរសំខាន់គឺ៖

១). ផលិតចែកចាយដល់សមាជិកក្រុមរបស់ខ្លួន

២). ផលិតលក់ដល់ទីផ្សារក្នុងនិងក្រៅសហគមន៍ដើម្បីយកប្រាក់ចំណូល សម្រាប់បន្តសកម្មភាពផលិតពូជដំណាំ។

លទ្ធផលរំពឹងទុកនៃការរៀបចំថ្នាលបណ្តុះពូជដំណាំនេះ នឹងធ្វើឲ្យកសិករមានពូជដំណាំសម្រាប់ផ្គត់ផ្គង់ក្នុងនិងក្រៅសហគមន៍ប្រកបដោយគុណភាពខ្ពស់ និងមានតម្លៃសមរម្យ។

## ៣. វិធីសាស្ត្រអនុវត្ត

ថ្នាលបណ្តុះពូជដំណាំសំដៅលើថ្នាលដែលបណ្តុះពូជដំណាំមួយ ឬច្រើនប្រភេទទោះបីជាដាំនៅលើដីផ្ទាល់ជាឡូតិ៍ (plot/lot plantation) ឬបណ្តុះក្នុងថ្នាលក្រោមសំណាញ់បៃតង (green net shelter)។ ពូជកូនដំណាំមានជាអាទ៏ម្នាស់ ស្វាយចន្ទី ក្រូចថ្លុង ក្រូចពោធិ៍សាត់ ក្រូចឆ្មា ដូងក្រអូប និងរុក្ខជាតិហូបផ្លែដទៃទៀត តាមវិធីសាស្ត្របណ្តុះ ដាំ សាកមែកក្នុងថ្នាលទុកជាដើមពូជ (Root stocks) ដើម្បីបង្កើតជាពូជកូនដំណាំ ឧទាហរណ៍ ដូចជាកូនម្នាស់(suckers) ឬដើមក្រូចថ្លុង ក្រូចឆ្មា ឬ អំបូរក្រូច (Citrus)សម្រាប់យកមកសាកមែកបំបៅមែក តមែក ភ្ជាប់ភ្នែក តត្រួយ និងពពួកកូនដំណាំផ្សេងៗទៀតដែលបណ្តុះចេញពីគ្រាប់ផ្ទាល់ (seedlings from seeds) ហើយមានរយៈពេលខ្លី មធ្យម ឬវែងតាមប្រភេទពូជរបស់វា។

### វិធីសាស្ត្រអនុវត្ត

- ❑ ដាំកូនផ្ទាល់ទុកជាដើមពូជ (Root stocks) ឧទាហរណ៍ៈ ដូចជាដាំកូនម្នាស់ក្នុងរយៈពេលមួយឲ្យបានជាកូនម្នាស់ (Pineapple suckers)
- ❑ សាកមែក បំបៅមែក តមែក ភ្ជាប់ភ្នែក តត្រួយ (layering, bud grafting, V grafting)
- ❑ បណ្តុះពីគ្រាប់ (from seeds) ដើម្បីបង្កើតជាពូជដំណាំ ពូជដំណាំជាលក្ខណៈដាំផ្ទាល់ (direct seeding) ឬបណ្តុះក្នុងថង់ផ្លាស្ទិច (seed germination/propagation) ឬរបៀបថ្មីៗផ្សេងទៀត។
- ➢ រយៈពេលខ្លី មធ្យម ឬវែងតាមប្រភេទពូជរបស់វា ( ១-៦, ៦-១២ ឬ លើស ១២ខែ )

គោលបំណង២
សំខាន់គឺ
១ ). ផលិតចែកចាយ
ដល់សមាជិកក្រុម
របស់ខ្លួន

២ ). ផលិតលក់
ដើម្បីបន្តសកម្មភាព
ផលិតកូនដំណាំឬ
ពូជដំណាំ។

## ៤. ដំណើរការរៀបចំថ្នាលបណ្តុះពូជដំណាំ

**ការជ្រើសរើសទីតាំងថ្នាល និងកសិករៈ** មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអាជ្ញាធរមូលដ្ឋានធ្វើការជ្រើសរើស និងកំណត់ទីតាំងថ្នាលបណ្តុះពូជដំណាំឲ្យបានសមស្រប និងចុះ

ជ្រើសរើសកសិករដែលមានសក្ដានុពលសម្រាប់រៀបចំថ្នាលបណ្ដុះពូជដំណាំតាមផែនការ។ រៀបចំគម្រោងផែនការវិនិយោគសម្រាប់បណ្ដុះពូជដំណាំដោយមានការចូលរួមបដិភាគក្នុងក្របខ័ណ្ឌកម្មវិធី ASPIRE ដល់សហគ្រាសអាជីវកម្ម (ថ្នាលបណ្ដុះពូជដំណាំ)ជារបៀបកិច្ចសន្យាផលិតពូជដំណាំ និងជួយសម្របសម្រួល និងផ្ដល់បច្ចេកទេសដល់សហគ្រាសអាជីវកម្មឲ្យដំណើរការថ្នាលបណ្ដុះពូជដំណាំ។

**ការជ្រើសរើសកសិកររៀបចំថ្នាលបណ្ដុះពូជដំណាំ៖** កសិករដែលមានសក្ដានុពលជាលក្ខណៈឯកជនដែលជាសមាជិកក្រុមកសិករសិក្សាខ្នាតតូច ឬមិនមែនជាសមាជិកក្រុម (SLG or Non-SLG)។ រៀបចំផែនការសកម្មភាពថវិកាដើម្បីចុះកិច្ចសន្យាជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចូលរួមបដិភាគជាសាច់ប្រាក់ ឬជាសម្ភារតាមលទ្ធភាពជាក់ស្ដែង។ បែងចែកកូនដំណាំដល់សមាជិក២៥នាក់តាមការព្រមព្រៀងគ្នា និងកត់ត្រារាល់ការលក់ និងសមាជិកទទួលផល។

**កសិករទទួលផល៖** សមាជិកទទួលផលយ៉ាងតិច២៥គ្រួសារពីថ្នាលបណ្ដុះពូជដំណាំ។ ជាសមាជិកក្រុមសិក្សាខ្នាតតូច ឬសមាជិកថ្មីដែលបានជ្រើសរើសសម្រាប់ទទួលផលពីការចែកពូជដំណាំយកមកដាំជាលក្ខណៈគ្រួសារ។ ចំពោះចំនួនកូនឈើត្រូវចែក គឺតាមការឯកភាពផ្ទៃក្នុងរបស់សមាជិកទទួលផល និងម្ចាស់ថ្នាល។

**ដំណើរការរៀបចំថ្នាលបណ្ដុះពូជដំណាំ៖**

**មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ**

- កំណត់ទីកន្លែងនិងកសិករដែលមានសក្ដានុពលសម្រាប់រៀបចំថ្នាល
- ផ្ដល់កញ្ចប់ថវិកា ៣០០០ដុល្លារ ដល់សហគ្រាសអាជីវកម្ម (ថ្នាលបណ្ដុះពូជដំណាំ) ជារបៀបកិច្ចសន្យាផលិតពូជដំណាំ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួយសម្របសម្រួលនិងផ្ដល់បច្ចេកទេសដល់សហគ្រាសអាជីវកម្ម

**អ្នករៀបចំថ្នាលបណ្ដុះពូជដំណាំ**

- ជាលក្ខណៈឯកជនដែលមានសក្ដានុពល(សមាជិកក្រុមសិក្សាខ្នាតតូច ឬសមាជិកថ្មី)
- រៀបចំផែនការសកម្មភាពថវិកា ៣០០០ដុល្លារ ដើម្បីចុះកិច្ចសន្យាជាមួយមន្ទីរ
- បដិភាគ (ជាសាច់ប្រាក់ឬសម្ភារ)
- បែងចែកកូនដំណាំដល់សមាជិក ២៥នាក់តាមការព្រមព្រៀងគ្នា
- កត់ត្រារាល់ការលក់ និងសមាជិកទទួលផល

**សមាជិកទទួលផល ២៥គ្រួសារ**

- សមាជិកទទួលផលយ៉ាងតិច២៥គ្រួសារពីថ្នាលបណ្ដុះពូជដំណាំ
- ជាសមាជិកក្រុមសិក្សាខ្នាតតូច ឬសមាជិកថ្មី
- ចំនួនកូនឈើត្រូវចែក (តាមការឯកភាពផ្ទៃក្នុងរបស់ក្រុម)

(ប្រភព៖ លទ្ធផលប្រជុំបច្ចេកទេសលើកទី៥ នៅខេត្តស្ទឹងត្រែង)

➢ **ការជ្រើសរើសទីតាំងថ្នាលបណ្តុះពូជដំណាំ**

- ថ្នាលបណ្តុះពូជដំណាំដែលសមស្រប គួរជ្រើសរើសលើទីតាំងដែលមានលក្ខណៈអំណោយផល និងមានផ្លូវចេញចូលទៅថែទាំ គ្រប់គ្រង ប្រមូលផល ឬដឹកជញ្ជូនបាន។ ការជ្រើសរើសទីតាំងនៅជិតផ្លូវចេញចូលមានលក្ខណៈងាយស្រួលដឹកជញ្ជូនសម្ភារ ឬដឹកជញ្ជូនកូនដំណាំផងដែរ។ បើលក្ខណៈជាថ្នាលបង្ហាញវិញ ការជ្រើសរើសជិតផ្លូវ និងមានមនុស្សធ្វើដំណើរច្រើនមានលក្ខណៈសមស្របក្នុងការបង្ហាញ
- ជិតប្រភពទឹកស្រោចស្រពរួមមានបឹងបួរ ត្រពាំង ឬស្រះដែលអាចយកទឹកមកស្រោចស្រពបានគ្រប់ពេលតាមតម្រូវការទោះបីជាខែប្រាំងក៏ដោយ
- ទីតាំងថ្នាល ជាដីមិនលិចទឹកនៅរដូវវស្សា ដីមិនជាំទឹក ឬដីអាចរៀបចំការបង្ហូរទឹកចេញបាននៅពេលមានទឹកដក់ច្រើនក្នុងថ្នាល។

**ការជ្រើសរើសទីតាំងថ្នាលបណ្តុះពូជដំណាំ៖**




(**ប្រភព៖**ថ្នាលបណ្តុះកូនឈើរបស់កម្មវិធីហារវែសនិង រូបភាពថ្នាលដាំម្នាស់របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង និងថ្នាលបង្ហាញដំណាំ របស់ក្រុមហ៊ុនមិត្តកសិករចំណាន)

## ៥. ការរៀបចំផែនការសកម្មភាព និងកិច្ចសន្យា

មន្ត្រីបច្ចេកទេសនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការជាមួយម្ចាស់ថ្នាលបណ្តុះពូជដំណាំក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាចំណាយព្រមទាំងចំនួនបដិភាគចូលរួមរបស់ម្ចាស់ថ្នាល។ ការរៀបចំសកម្មភាពនិងថវិកាលម្អិតដើម្បីភ្ជាប់ជាឯកសារចុះកិច្ចសន្យាជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ដូចមាន**ភ្ជាប់ឧបសម្ព័ន្ធទី១៖ គំរូកិច្ចសន្យាសម្រាប់ថ្នាលបណ្តុះពូជដំណាំ និង ឧបសម្ព័ន្ធទី២៖ គំរូផែនការសកម្មភាពនិងថវិកា។**

## ៦. ការបែងចែកកូនដំណាំដល់សមាជិកទទួលផល

ម្ចាស់ថ្នាលបណ្តុះពូជដំណាំត្រូវធ្វើការបែងចែកកូនដំណាំដែលបានបណ្តុះរួចដែលមានអាយុគ្រប់គ្រាន់អាចដាំបានមកដល់សមាជិកទទួលផលចំនួនយ៉ាងតិច២៥គ្រួសារដែលបានជ្រើសរើសកំឡុងពេលបណ្តុះពូជកូនដំណាំ។ ដោយមានការសម្របសម្រួលពីមន្ត្រីបច្ចេកទេសនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ម្ចាស់ថ្នាលត្រូវជួយរៀបចំនិងជ្រើសរើសកសិករដែលជាសមាជិកទទួលផលឲ្យរួចជាស្រេចមុនពេលចែកចាយកូនដំណាំ។

ចំនួនកូនដំណាំនិងពេលវេលាត្រូវចែកចាយដល់សមាជិកទទួលផលនឹងត្រូវធ្វើការឯកភាពផ្ទៃក្នុង។ ជាមូលដ្ឋានក្នុងការបែងចែកកូនដំណាំ ម្ចាស់ថ្នាលនិងសមាជិកទទួលផល អាចធ្វើការពិភាក្សាលើចំនួន ៤0% សម្រាប់ចែកដល់សមាជិក២៥គ្រួសារ និង៦0%សម្រាប់ម្ចាស់ថ្នាលបន្តនិរន្តរភាពថ្នាល។ ការបែងចែកនិងលក់កូនដំណាំទាំងអស់ម្ចាស់ថ្នាលត្រូវធ្វើការកត់ត្រាក្នុងតារាងដូចក្នុង**ឧបសម្ព័ន្ធទី៣៖ គំរូតារាងតាមដានការកត់ត្រាចំនួនកូនដំណាំ។**

## ៧. តាមដានអនុវត្តសកម្មភាព និងតម្រង់ទិស

មន្ត្រីបច្ចេកទេសនៃកម្មវិធី ASPIRE របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពថ្នាលបណ្តុះកូនដំណាំជាប្រចាំតាមពេលវេលាដែលបានព្រមព្រៀងគ្នា ដើម្បីឲ្យប្រាកដថាសកម្មភាពសំខាន់ៗត្រូវបានយកមកអនុវត្តហើយចូលរួមដោះស្រាយលើរាល់បញ្ហាជួបប្រទះបានទាន់ពេលវេលា រួមទាំងការគ្រប់គ្រងថ្នាល និងបច្ចេកទេស។ ការតាមដាននេះជួយតម្រង់ទិសក្នុងការអនុវត្តសកម្មភាពឲ្យបានរលូនតាមបច្ចេកទេស។

មន្ត្រីកសិកម្មស្រុក/ក្រុងចូលរួមតាមដានការអនុវត្តសកម្មភាពថ្នាលបណ្តុះកូនដំណាំ និងសម្របសម្រួលជាមួយម្ចាស់ថ្នាលក្នុងការផលិត និងចែកចាយកូនដំណាំ ហើយធ្វើការរាយការណ៍ពីការរីកចម្រើនជាប្រចាំមកមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃនៃកម្មវិធី ASPIRE របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៕

ឧបសម្ព័ន្ធទី១៖ គំរូកិច្ចសន្យាសម្រាប់ថ្នាលបណ្ដុះពូជដំណាំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**
( ASPIRE )

IFAD Loan No. 2000000744 និង ASAP Trust Grant No. 2000000743

# កិច្ចសន្យាសម្រាប់ថ្នាលបណ្ដុះពូជដំណាំ

## កិច្ចសន្យានេះ ធ្វើឡើងរវាង

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត .......................................ដែលមានអាសយដ្ឋានស្ថិតនៅ ភូមិ ............................ឃុំ/សង្កាត់............................ក្រុង..........................ខេត្ត..................... ដែលតំណាងឲ្យកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដោយលោកឈ្មោះ...................................................ជាប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានអនុកម្មវិធីថ្នាក់ខេត្ត ហៅកាត់ថាភាគី (ក) ។

ជាមួយនឹង

កសិករម្ចាស់ថ្នាលបណ្តុះពូជដំណាំ លោក/លោកស្រីឈ្មោះ.................................... និងប្រពន្ធ/ប្តីឈ្មោះ....................................មានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ ................................................ ឃុំ.........................ស្រុក........................ខេត្ត............................... ជាម្ចាស់ថ្នាលបណ្តុះពូជដំណាំកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ....................................ហៅថាភាគី (ខ)។

## ភាគីទាំងពីរបានឯកភាពគ្នារាល់ប្រការដូចមានចែងខាងក្រោម៖

**ប្រការ១៖**ភាគី (ក)បានជ្រើសរើសយកភាគី (ខ) ដែលមានសក្តានុពលក្នុងការទទួលរៀបចំថ្នាលបណ្តុះពូជដំណាំក្នុងការផ្គត់ផ្គង់ និងចែកចាយពូជដំណាំដល់សមាជិកអ្នកទទួលផលដែលបានជ្រើសរើសចំនួនយ៉ាងតិច២៥គ្រួសារ និងលក់ធ្វើអាជីវកម្មដែលអនុវត្តតាមលក្ខខណ្ឌនៃកម្មវិធី (ASPIRE)។

**ប្រការ២៖**ភាគី(ក) ផ្តល់ថវិកាដល់ភាគី (ខ) តាមគម្រោងផែនការវិនិយោគសម្រាប់បណ្តុះពូជដំណាំនិងមានការចូលរួមបដិភាគក្នុងក្របខណ្ឌកម្មវិធី(ASPIRE) ក្នុងតម្លៃទឹកប្រាក់សរុប **៣,000** ដុល្លារអាមេរិក (ជា អក្សរ=**បីពាន់ដុល្លារអាមេរិកគត់**) ក្នុងនោះមិនរាប់បញ្ចូលទឹកប្រាក់បដិភាគពីភាគី (ខ)។

ភាគី(ក) ផ្តល់ជូនភាគី (ខ) នូវថវិកាជា **0២** ដំណាក់កាល សម្រាប់ដំណើរការរៀបចំថ្នាលបណ្តុះកូនដំណាំ ដូចខាងក្រោម៖

- **ដំណាក់កាលទី 0១៖** ផ្តល់ថវិកាចំនួន ៥0%នៃកិច្ចសន្យា ស្មើនឹង **១៥00**ដុល្លារអាមេរិក បន្ទាប់ពីចុះកិច្ចសន្យា និងរៀបចំដំឡើងថ្នាលថ្នាលបណ្តុះពូជដំណាំ៖
  - សម្ភារ និងឧបករណ៍ ប្រព័ន្ធស្រោចស្រព
- **ដំណាក់កាលទី 0២៖** ផ្តល់ថវិកាចំនួន ៥0% នៃកិច្ចសន្យា ស្មើនឹង**១៥00**ដុល្លារអាមេរិក បន្ទាប់ពីរៀបចំថ្នាលបណ្តុះកូនដំណាំ នៃដំណាក់កាលទី ១ នៃកិច្ចសន្យា
  - កូនដំណាំ គ្រាប់ពូជ ថង់ផ្លាស្ទិច ស្បៃ និងសម្ភារ បរិក្ខារនានាសម្រាប់ដំណើរការថ្នាល។
- ថវិកាកម្មវិធីនេះ មិនរាប់បញ្ចូលការបដិភាគពីភាគី(ខ)ទេ។ ចំនួនបដិភាគនេះគិតផ្អែកលើលទ្ធភាពរបស់កសិករម្ចាស់ថ្នាល ជាថវិកាផ្ទាល់ ឬជាសម្ភារបរិក្ខារ។

**ប្រការ៣៖**ភាគី (ខ) បានឯកភាពទទួលយកការងាររៀបចំ និងដំណើរការថ្នាលបណ្តុះពូជដំណាំជូនភាគី (ក) ក្នុងតម្លៃដែលមានចែងក្នុងប្រការ ២ ខាងលើ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

**ប្រការ៤៖**ភាគី(ក)នឹងធ្វើការសហការជាមួយក្រុមការងារនៃការិយាល័យកសិកម្មស្រុក/ក្រុង ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់ភាគី(ខ) ដូចមានចែងក្នុងប្រការ ៣។

**ប្រការ៥៖**ភាគី (ខ) មានភារៈកិច្ចរាយការណ៍និងកត់ត្រារាល់វឌ្ឍនភាពនៃការរៀបចំថ្នាល ការបណ្តុះពូជដំណាំ ជូនភាគី(ក) ឲ្យបានទាន់ពេលវេលាកំណត់។

**ប្រការ៦៖**ភាគី (ខ) មានភារៈកិច្ចទទួលខុសត្រូវក្នុងការចាត់ចែង គ្រប់គ្រងថ្នាលបណ្តុះពូជដំណាំ ដូចចែងក្នុងប្រការ១ និងចែកចាយកូនដំណាំដែលមានអាយុគ្រប់គ្រាន់អាចយកមកដាំបាន ឲ្យបានទាន់ពេលពេលវេលាដល់សមាជិកទទួលផលយ៉ាងតិច២៥គ្រួសារដែលបានជ្រើសរើស។ ភាគី (ខ) ត្រូវរៀបចំពិភាក្សាដោយសហការជាមួយមន្ត្រីពីភាគី(ក)លើការឯកភាពជាមួយសមាជិកទទួលផលទាំងអស់ពីចំនួនកូនដំណាំដែលត្រូវចែកចាយមកដាំតាមគ្រួសារ។

**ប្រការ៧៖** ភាគី (ក) និង ភាគី (ខ) បើភាគីណាមួយកត់សម្គាល់ឃើញមានបញ្ហា ត្រូវអញ្ជើញភាគីម្ខាងទៀតមកពិភាក្សា និងដោះស្រាយដោយឈរលើគោលការណ៍ និងស្មារតីសហការយោគយល់គ្នាដោយសន្តិវិធី។ ក្នុងករណីភាគីទាំងពីរ មិនអាចដោះស្រាយបញ្ហាបាន ត្រូវបញ្ជូនសំណុំរឿងទៅប្រធានកម្មវិធីថ្នាក់ខេត្ត ដើម្បីសុំការសម្រេចជាចុងក្រោយ។

**ប្រការ៨៖**កិច្ចសន្យានេះ ធ្វើឡើងចំនួន ០២ ច្បាប់ ដែលមានខ្លឹមសារ និងតម្លៃផ្លូវច្បាប់ដូចគ្នា ក្នុងនោះចំនួន ០១ ច្បាប់ត្រូវរក្សាទុកនៅភាគី (ខ) និង ០១ ច្បាប់រក្សាទុកនៅភាគី(ក) ។

**ប្រការ៩៖** បន្ទាប់ពីចុះហត្ថលេខាលើកិច្ចសន្យានេះ ភាគីទាំងពីរត្រូវគោរព និងអនុវត្តតាមគ្រប់ប្រការដែលមានចែងខាងលើ។

**ប្រការ១០៖**កិច្ចសន្យានេះ មានប្រសិទ្ធភាពចាប់ពីចុះហត្ថលេខានេះតទៅ។

ធ្វើនៅថ្ងៃទី...............ខែ............ឆ្នាំ.......

ប្រធានការិយាល័យកសិកម្មស្រុក　　　　មេភូមិ　　　　កសិករម្ចាស់ថ្នាល ភាគី (ខ)

បានឃើញ និងឯកភាព

ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ

ហត្ថលេខា

## ឧបសម្ព័ន្ធទី២៖ គំរូផែនការសកម្មភាព និងថវិកា

| លរ | សកម្មភាព | លទ្ធផលរំពឹងទុក | ពេលវេលា/ ទីកន្លែង | អ្នកទទួល ខុសត្រូវ | ថវិកា |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| 7 | | | | | |
| 8 | | | | | |
| 9 | | | | | |
| 10 | | | | | |

## ឧបសម្ព័ន្ធទី៣៖ គំរូតារាងតាមដានការកត់ត្រាចំនួនកូនដំណាំ

| លរ | កាលបរិច្ឆេទ | ប្រភេទ កូនដំណាំ | ចំនួន | ថវិកា | ឈ្មោះអ្នកទទួល/ អ្នកទិញ | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| 7 | | | | | | |
| 8 | | | | | | |
| 9 | | | | | | |
| 10 | | | | | | |



**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**

អាសយដ្ឋាន៖ # ២០០ផ្លូវនរោត្តមសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

លេខទូរស័ព្ទ៖ ០២៣ ២២ ១១ ២០

គេហទំព័រ៖WWW.ASPIREKH.ORG

IFAD
Investing in rural people